ISSN 1810-6358

វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា

**Cambodia Development Resource Institute**

# របាយការណ៍ថ្មីៗស្តីពីសេដ្ឋកិច្ចកម្ពុជា

# Flash Report on the Cambodian Economy

កក្កដា ២០០៧ / July 2007

ផាន់ ដាលីស / **Phann Dalis**

ប៉ុន ដូរីណា / **Pon Dorina**

ហ៊ីង វុត្ថា / **Hing Vutha**

ភឹម រុនស៊ីណារិទ្ធិ / **Phim Runsinarith**

បកប្រែដោយ: **យូ សិទ្ធីរិទ្ធ និង យេន សុផានី**

## ភ្នំពេញ កម្ពុជា

## Phnom Penh, Cambodia

**TO SUBSCRIBE, PLEASE CONTACT:**

*Office Address:* #56, Street 315, Tuol Kork, Phnom Penh, Cambodia, *Postal Address:* CDRI, PO Box 622 Phnom Penh, Cambodia
*Tel:* (855-23) 881-384/881-701/881-916/883-603 *Fax:* (855-23) 880-734 *E-mail:* pubs@cdri.forum.org.kh. *Web site:* http://www.cdri.org.kh

# សកម្មភាពសេដ្ឋកិច្ចសំខាន់ៗរបស់កម្ពុជា
# Main Economic Activities of Cambodia

នៅត្រីមាសទី១ ឆ្នាំ២០០៧ គំរោងវិនិយោគឯកជនក្នុងវិស័យសេវាកម្មបានអនុម័តមានចំនួន ៣៣៥,៧លានដុល្លារ រឺថយចុះ ៥៥% ធៀបនឹងត្រីមាសមុន ។ គំរោងអនុម័តក្នុងវិស័យទេសចរណ៍មាន ៤២% នៃគំរោងអនុម័តក្នុងវិស័យសេវាកម្ម រឺធ្លាក់ចុះ ៥៦% ធៀបនឹងត្រីមាសមុន ។ ប៉ុន្តែ គំរោងវិនិយោគក្នុងវិស័យសេវាកម្មកើនឡើង ៦ដង នៅត្រីមាសដូចគ្នា ឆ្នាំ២០០៦ (៦០,៧លានដុល្លារ) ។

Services sector private investment approvals in the first quarter 2007 were USD 335.7 m, a decline of 55 percent compared to the preceding quarter. Tourism sub-sector approvals were 42 percent of services sector approvals, a decrease of 56 percent from the previous quarter. Investment approvals in the services sector, however, increased in value by six times in the same quarter in 2006 (USD 60.7 m).

**Private Investment in Service Sector Approvals by CDC**
2004 Q2–2007 Q1




*Including expansion projects*
Source: Council for the Development of Cambodia

នៅខែមេសា ឆ្នាំ២០០៧ ចំនួនភ្ញៀវសរុបមកដល់កម្ពុជា ធ្លាក់ចុះ ៧,៥% ធៀបនឹងខែមុន មកត្រឹម ១៦៥.៣៤៧នាក់ ។ ចំនួនភ្ញៀវមកដល់តាមផ្លូវអាកាសធ្លាក់ចុះ ១៦% មកត្រឹម ១០០.១១៣នាក់ រីឯតាមផ្លូវគោក និងផ្លូវទឹក កើនឡើង ៩,៤% ដល់ ៦៥.២៣៤នាក់ ។ ក្នុងចំណោមភ្ញៀវសរុប ភ្ញៀវមកសំរាកលំហែមាន ៨០% រឺថយចុះ ១៧% ធៀបនឹងខែមុន ។ ធៀបនឹងខែដូចគ្នាឆ្នាំ២០០៦ ភ្ញៀវមកសំរាកលំហែកើន ២១% ។ ជាធម្មតា ចំនួនភ្ញៀវមកសំរាកលំហែធ្លាក់ចុះនៅខែមេសា ដោយសារអាកាសធាតុក្តៅ ។

In April 2007, total visitor arrivals to Cambodia decreased by 7.5 percent from the previous month to 165,347. Visitor arrivals by air fell by 16 percent to 100,113, while overland and by water they increased by 9.4 percent to 65,234. Of total visitor arrivals, those entering the country for holiday purposes were 80 percent, a decrease of 17 percent from the preceding month. Compared to the same month in 2006, holiday visitors increased by 21 percent. The number of tourists normally falls in April due to the heat.

**Cambodia: Foreign Visitor Arrivals**
January 2006–April 2007




Source: Ministry of Tourism

នៅខែមេសា ឆ្នាំ២០០៧ អនុមតិគំរោងសាងសង់នៅភ្នំពេញធ្លាក់ចុះ ៥៦% ធៀបនឹងខែមុន មកត្រឹម ១១,៨លានដុល្លារ ។ អនុមតិសំណង់ផ្ទះល្វែង និងភូមិគ្រឹះនិងផ្ទះ ធ្លាក់ចុះ ៧៨% មកត្រឹម ៤,៥លានដុល្លារ និង ៦៨% មកត្រឹម ០,៩លានដុល្លារ ។ នៅខែមេសា ឆ្នាំ២០០៧ អនុមតិគំរោងសាងសង់សរុបធ្លាក់ចុះបន្តិចអស់ ០,០២% ធៀបនឹងខែដូចគ្នា ឆ្នាំ២០០៦ ។

Phnom Penh construction approvals in April 2007 decreased by 56 percent from the preceding month, to USD 11.8 m, of which construction of flats, and villa and house construction approvals dropped by 78 percent to USD 4.5 m and 68 percent to USD 0.9 m, respectively. Total construction approvals in April 2007 decreased slightly by 0.02 percent from the same month in 2006.

**Phnom Penh: Value of Construction Approvals**
January 2006–April 2007




Source: Phnom Penh Municipality

# ថ្លៃទំនិញ និង ស្ថានភាពពលករងាយរងគ្រោះ
# Consumer Prices and Vulnerable Workers Survey

នៅខែឧសភា ឆ្នាំ២០០៧ ថ្លៃទំនិញទូទៅនៅភ្នំពេញ កើន 0,៧% ធៀបនឹងខែមុន ក្នុងនោះ ថ្លៃម្ហូបអាហារ កើន ១,៣% រីឯ ថ្លៃទូរគមនាគមន៍និងដឹកជញ្ជូន កើន ១,៩% ។ ធៀបនឹងខែដូចគ្នា ឆ្នាំ២០០៦ ថ្លៃទំនិញគ្រប់មុខ កើន ៤,១% ក្នុងនោះ ថ្លៃម្ហូបអាហារ និង ថ្លៃទូរគមនាគមន៍និងដឹកជញ្ជូន កើន ៥,៦% និង ៦,0% ។

In May 2007, overall prices in Phnom Penh increased by 0.7 percent from the preceding month, of which food prices, and telecommunication and transportation costs rose by 1.3 percent and 1.9 percent, respectively. Compared to the same month in 2006, the price of all items rose by 4.1 percent; food prices, and telecommunication and transportation values went up by 5.6 percent and 6.0 percent respectively.

**Phnom Penh: Consumer Price Index**
(July–December 2000=100)
February 2006–May 2007




Source: National Institute of Statistics

នៅខែមិថុនា ឆ្នាំ២០០៧ ប្រេងសាំងលក់ថ្លៃជាមធ្យម ៣៩៤0រៀល/លីត្រ រីឯ ម៉ាស៊ូត ថ្លៃ ៣0៩0រៀល/លីត្រ ។ ប្រេងសាំងឡើងថ្លៃ ១,៤% ធៀបនឹងខែមុន និងធ្លាក់ថ្លៃ ៣,៦% ធៀបនឹងខែដូចគ្នា ឆ្នាំ២០០៦ ។ ថ្លៃម៉ាស៊ូត នៅនឹងដដែលធៀបនឹងខែមុន ប៉ុន្តែវាធ្លាក់ថ្លៃ ៣,៧% ធៀបនឹងខែដូចគ្នា ឆ្នាំ២០០៦ ។

In June 2007, gasoline prices averaged 3940 riels/ℓ, while diesel sold at 3090 riels/ℓ. Gasoline prices increased by 1.4 percent from the previous month and decreased by 3.6 percent from the same month in 2006. Diesel costs stayed the same, compared to the previous month; however, it dropped by 3.7 percent compared to the same month in 2006.

**Phnom Penh: Gasoline & Diesel Prices**
April 2006–June 2007




Sources: CDRI and National Institute of Statistics

នៅខែឧសភា ឆ្នាំ២០០៧ យោងតាមអង្កេតលើពលករងាយរងគ្រោះរបស់វបសអ ប្រាក់ចំណូលប្រចាំថ្ងៃពិតរបស់អ្នកធាក់ស៊ីក្លូ និងអ្នករត់ម៉ូតូឌុប កើន ៤១% ដូចគ្នា ដល់ ៩.២៤៥រៀល/ថ្ងៃ និង ១២.៨៨៦រៀល/ថ្ងៃ និងរបស់កម្មករសំណង់គ្មានជំនាញ កើន ១៩% ដល់ ៦.0៧៥រៀល/ថ្ងៃ ធៀបនឹងអង្កេតនៅខែកុម្ភៈ ។ ប្រាក់ចំណូលប្រចាំថ្ងៃពិតរបស់អ្នកធាក់ស៊ីក្លូ និងអ្នករត់ម៉ូតូឌុប កើនបាន ៨,២% និង ៤៧% រីឯប្រាក់ចំណូលរបស់កម្មករសំណង់គ្មានជំនាញ ធ្លាក់ចុះ ៥,២% ធៀបនឹងខែដូចគ្នា ឆ្នាំ២០០៦ ។

According to CDRI's Vulnerable Worker Survey in May 2007, the real daily earnings of cyclo drivers and motorcycle taxi-drivers rose at the same percent by 41 percent to 9,245 riels per day and 12,886 riels per day, and unskilled construction workers rose by 19 percent to 6,075 riels per day, compared to the February survey. Real daily earnings of cyclo drivers and motorcycle taxi-drivers increased by 8.2 percent and 47 percent, respectively, from the same month in 2006, while the income of unskilled construction workers dropped by 5.2 percent.

**Phnom Penh: Vulnerable Workers Real Daily Earnings**
November 2004–May 2007




Source: CDRI

# ស្ថានភាពអត្រាប្តូរប្រាក់ និង ជំនួយអភិវឌ្ឍន៍ពីក្រៅប្រទេស

# Exchange Rates and External Development Assistance

នៅខែមិថុនា ឆ្នាំ២០០៧ ទល់នឹងដុល្លារUS ប្រាក់រៀលប្តូរបាន ៤០៩៣.០រៀល/ដុល្លារUS រឺធ្លាក់ថ្លៃ ០.៥% ធៀបនឹងខែមុន ។ ធៀបនឹងខែដូចគ្នា ឆ្នាំ២០០៦ ប្រាក់រៀលឡើងថ្លៃ ០.៦% ទល់នឹងដុល្លារUS ។

In June 2007, the riel against the US dollar traded at 4093.0 riels/USD, a depreciation of 0.5 percent from the previous month. Compared to the same month in 2006, the riel appreciated by 0.6 percent against the US dollar.

**Riels per US Dollar**

April 2006–June 2007




Sources: National Bank of Cambodia and CDRI

នៅខែមិថុនា ឆ្នាំ២០០៧ ប្រាក់រៀលឡើងថ្លៃ ០.៧% ទល់នឹងប្រាក់បាតថៃ ធៀបនឹងខែមុន ដោយប្តូរបាន ១១៨.៨រៀល/បាត ។ ទល់នឹងប្រាក់ដុងវៀតណាម ប្រាក់រៀលប្តូរបាន ២៥.០រៀល/១០០ដុង រឺធ្លាក់ថ្លៃ ១.៣% ។ ធៀបនឹងខែមិថុនា ឆ្នាំ២០០៦ ប្រាក់រៀលឡើងថ្លៃ ០.៦% ទល់នឹងដុល្លារUS ប៉ុន្តែធ្លាក់ថ្លៃ ០.១% ទល់នឹងប្រាក់ដុងវៀតណាម និងធ្លាក់ថ្លៃ ១០% ទល់នឹងប្រាក់បាតថៃ ។

The riel appreciated by 0.7 percent against the Thai baht in June 2007 compared to the preceding month, trading at 118.8 riels/baht. In trading with the Vietnamese dong, the riel was 25.0 riels per 100 dong, depreciation of 1.3 percent. Compared with June 2006, the riel value was up by 0.6 percent against the US dollar; while with the Vietnamese dong and Thai baht it was down by 0.1 percent and 10 percent, respectively.

**Riels per THB & VND**

April 2006–June 2007




Source: CDRI

ពីឆ្នាំ១៩៩៦ ដល់ឆ្នាំ២០០៥ កម្ពុជាបានទទួលប្រាក់ជំនួយចំនួន ៣១៦.២ លានដុល្លារUS សំរាប់ការគ្រប់គ្រងសេដ្ឋកិច្ច រួមមាន ការរៀបចំគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច គោលនយោបាយរូបិយវត្ថុនិងសារពើពន្ធ និងការរៀបចំគោលនយោបាយការងារនិងជីវភាពរស់នៅ ។ នៅឆ្នាំ២០០៥ ប្រាក់ជំនួយមាន ១៥.២លានដុល្លារUS ដែលបានមកពីអ្នកផ្តល់ជំនួយជាច្រើន មានទាំង ធនាគារអភិវឌ្ឍន៍អាស៊ី ផង។

From 1996 to 2005, Cambodia was allocated USD 316.2 m for economic management assistance i.e., macro-economic policy planning, fiscal and monetary policy planning, and employment/livelihood policy planning. In 2005, allocated funds were USD 15.2 m; these funds were from many donors, including the ADB.

**External Development Assistance Disbursement:**

Economic Management Assistance 1996–2005




Source: CDC, Development Cooperation Report 04-05

# ការអភិវឌ្ឍន៍រូបិយវត្ថុ

# Monetary Developments

នៅខែមេសា ឆ្នាំ២០០៧ រូបិយវត្ថុទូទៅ (M2) កើនតាមអត្រាប្រចាំឆ្នាំ ៣២% រីឯការផ្គត់ផ្គង់រូបិយវត្ថុ (M1) ធ្លាក់ចុះតាមអត្រាប្រចាំឆ្នាំ ១១% ។ នៅរយៈ១២ខែមុន រូបិយវត្ថុទូទៅ (M2) កើនបាន ៣៥% ធៀបនឹងកំណើន ៣៧% នៅរយៈមួយឆ្នាំដល់ខែមីនា ឆ្នាំ២០០៧ ។

In April 2007, liquidity (M2) grew at an annualised rate of 32 percent and money supply (M1) decreased at an annualised rate of 11 percent. In the previous 12 months, liquidity (M2) grew by 35 percent, compared to growth of 37 percent in the year to March 2007.

**Monetary Survey**

February 2006–April 2007




Source: National Bank of Cambodia

ឥណទានក្នុងស្រុកធ្លាក់ចុះតាមអត្រាប្រចាំឆ្នាំ ១២% រីឯឥណទានក្នុងវិស័យឯកជនកើនតាមអត្រាប្រចាំឆ្នាំ ៣៣% នៅខែមេសា ឆ្នាំ២០០៧ ។ ក្នុងរយៈ១២ខែ ដល់ខែមេសា ឆ្នាំ២០០៧ ឥណទានក្នុងស្រុកកើន ៣៦% ធៀបនឹងកំណើន ៤៣% នៅរយៈមួយឆ្នាំដល់ខែមីនាឆ្នាំ២០០៧ ។

Domestic credit decreased at an annualised rate of 12 percent, while private sector credit grew at an annualised rate of 33 percent in April 2007. Over the twelve months to April 2007, domestic credit grew by 36 percent, compared to growth of 43 percent in the year to March 2007.

**Domestic Credit**

February 2006–April 2007




Source: National Bank of Cambodia

ឥណទានក្នុងវិស័យឯកជន និងទ្រព្យសកម្មបរទេសសុទ្ធ នៅខែមេសា ឆ្នាំ២០០៧ កើន ២.៤% ដល់ ៤១៦៥.៣ពាន់លានរៀល និង ៣.៦% ដល់ ៨៣៤៥.៣ពាន់លានរៀល ។ ឥណទានរបស់រដ្ឋាភិបាលធ្លាក់ចុះ ០.០៥% មកត្រឹម ២៩៧.៨ពាន់លានរៀល និងបញ្ញើរបស់រដ្ឋាភិបាល កើន ៨.៧% ដល់ ១៦០១.១ពាន់លានរៀល ហើយបំណុលផ្សេងទៀត កើន ២.៤% ដល់ ៣២៣១.៤ពាន់លានរៀល ។ បំលាស់ប្តូរនៃប្រតិបត្តិការរូបិយវត្ថុទាំងនេះ បានបង្កើនរូបិយវត្ថុទូទៅ ២.៤% ដល់ ៧៩៧៦.០ពាន់លានរៀល ។

Private sector credit and Net Foreign Assets (NFA) in April 2007 grew by 2.4 percent to 4165.3 billion riels and 3.6 percent to 8345.3 billion riels respectively. Government credit dropped by 0.05 percent to 297.8 billion riels, government deposits were up by 8.7 percent to 1601.1 billion riels, and 'other items' increased by 2.4 percent to 3231.4 billion riels. The change of these operations increased liquidity by 2.4 percent to 7976.0 billion riels.

**Changes in Monetary Assets**

February 2006–April 2007




Source: National Bank of Cambodia

# ពាណិជ្ជកម្មក្រៅប្រទេស
# External Trade

នៅខែមេសា ឆ្នាំ២០០៧ ការនាំចេញរបស់កម្ពុជាធ្លាក់ចុះ ២៩% ដល់ ១៦៦,៤លានដុល្លារ ធៀបនឹងខែមុន ។ ការនាំចេញត្រី សំលៀកបំពាក់ និង កៅស៊ូ ធ្លាក់ចុះ ១៧% មកត្រឹម ០,១លានដុល្លារ ២៨% មកត្រឹម ១៦៣,៩លានដុល្លារ និង ៧២% មកត្រឹម ០,៤លានដុល្លារ ។ ប៉ុន្តែ ធៀបនឹងខែដូចគ្នា ឆ្នាំ២០០៦ ការនាំចេញសរុប កើន ១១% ដែលក្នុងនោះ ការនាំចេញសំលៀកបំពាក់ កើន ១៣% រីឯ ការនាំចេញត្រី និងកៅស៊ូ ធ្លាក់ចុះ ៧៣% និង ៨៣% ។

In April 2007, Cambodian exports fell by 29 percent to USD 166.4 m, compared to the preceding month. Fish, garment and rubber exports decreased by 17 percent to USD 0.1 m, 28 percent to USD 163.9 m and 72 percent to USD 0.4 m, respectively. Compared to the same month in 2006, however, total exports increased by 11 percent, of which garment exports were up by 13 percent, while fish and rubber exports dropped by 73 percent and 83 percent, respectively.

**Cambodia: Main Exports**
February 2006–April 2007




Source: Customs and Excise Department

នៅខែមេសា ឆ្នាំ២០០៧ ការនាំចូលបារី កើនមួយជាបី ធៀបនឹងខែមុន ដល់ ៣៨,៣ពាន់លានរៀល រីឯការនាំចូលដែក និងស៊ីម៉ង់ត៍ ធ្លាក់ចុះ ៣៣% មកត្រឹម ១៧,៦ពាន់លានរៀល និង ៣៩% មកត្រឹម ១៥,៨ពាន់លានរៀល។ ធៀបនឹងខែដូចគ្នា ឆ្នាំ២០០៦ ការនាំចូលបារី និងដែក កើន ៨,៥% និង ៤១% រីឯការនាំចូលស៊ីម៉ង់ត៍ ធ្លាក់ចុះអស់ ១៤% ។

In April 2007, cigarette imports increased by three times the value of the previous month to 38.3 billion riels, while steel and cement imports dropped by 33 percent to 17.6 billion riels and 39 percent to 15.8 billion riels respectively. Compared to the same month in 2006, cigarette and steel imports increased by 8.5 percent and 41 percent respectively, while cement imports declined by 14 percent.

**Imports: Cigarettes & Construction Materials**
February 2006–April 2007




Source: Customs and Excise Department

ការនាំចូលសាំងនៅខែមេសា ឆ្នាំ២០០៧ កើន ១១% ធៀបនឹងខែមុន ដល់ ១៩.៧៥៣តោន និងការនាំចូលម៉ាស៊ូត កើន ៨.៥% ដល់ ៤១.៨៦១តោន។ បើពិនិត្យលើតំលៃ ការនាំចូលសាំងមាន ២៤.៨ពាន់លានរៀល និង ការនាំចូលម៉ាស៊ូតមាន ៤៥.៣ពាន់លានរៀល ។

Imports of gasoline in April 2007 rose by 11 percent from the previous month to 19,753 tonnes and diesel imports increased by 8.5 percent to 41,861 tonnes. In terms of value, imports were: gasoline, 24.8 billion riels and diesel, 45.3 billion riels.

**Imports: Petroleum Products**
February 2006–April 2007




Source: Customs and Excise Department

# ការអនុវត្តន៍ថវិកាជាតិ
# National Budget Operations

តុល្យភាពថវិកាចរន្ត មានការប្រែប្រួលឡើងចុះ ចាប់តាំងពីខែកញ្ញា ឆ្នាំ២០០៦ ។ នៅខែមករា ឆ្នាំ២០០៧ អតិរេកថវិកាចរន្ត គឺ ២៣២,០ ពាន់លានរៀល ធៀបនឹងឱនភាព ៣០,០ពាន់លានរៀល កាលពីខែមុន ។ អតិរេកមានកំរិត ៣៩% ច្រើនជាងនៅខែដូចគ្នា ឆ្នាំ២០០៦ ។

The current budget balance has fluctuated since September 2006. In January 2007, the current budget surplus was 232.0 billion riels, compared to the deficit of 30.0 billion riels in the previous month. The surplus was 39 percent more than the value in the same month in 2006.

**Current Budget Operations**
August 2005–January 2007




*Note: Provisional for2006 and 2007*
Source: *Monthly Bulletin of Statistics* (MEF)

នៅខែមករា ឆ្នាំ២០០៧ ចំណូលថវិកាចរន្ត ថយចុះ ២៩% ធៀបនឹងខែមុន មកត្រឹម ២៥៨,០ពាន់លានរៀល ។ ការប្រមូលពន្ធក្នុងស្រុក កើនមួយជាពីរ ដល់ ១៥០,៣ពាន់លានរៀល រីឯពន្ធនាំចេញនាំចូល ថយចុះ ៦២% មកត្រឹម ៧២,២ពាន់លានរៀល និងចំណូលមិនមែនពន្ធ ថយចុះ ៦៤% មកត្រឹម ៣៥,៥ពាន់លានរៀល ។

In January 2007, current budget revenue decreased by 29 percent from the previous month to 258.0 billion riels. Domestic tax collections doubled to 150.3 billion riels, while import and export tax, and non-tax revenue decreased by 62 percent to 72.2 billion riels and 64 percent to 35.5 billion riels percent respectively.

**Current Budget Revenue**
August 2005–January 2007




*Note: Provisional for 2006 and 2007*
Source: *Monthly Bulletin of Statistics* (MEF)

នៅខែមករា ឆ្នាំ២០០៧ ចំណាយថវិកាចរន្ត ថយចុះ ៩៣% ធៀបនឹងខែមុន មកត្រឹម ២៥,៨ពាន់លានរៀល ។ ចំណាយលើបៀវត្សរ៍មន្ត្រីរាជការ គឺ ១៣,៧ពាន់លានរៀល ហើយឧបត្ថម្ភធនរបស់រដ្ឋាភិបាល និងជំនួយសង្គមកិច្ច គឺ ៤,០ពាន់លានរៀល ។ យោងតាម ការត្រួតពិនិត្យនិងកែលំអរបស់ក្រសួងហិរញ្ញវត្ថុ នៅខែមករា ឆ្នាំ២០០៧ ថវិការដ្ឋាភិបាលបានប្រែប្រួល។ បច្ចុប្បន្នរបាយការណ៍ត្រូវបានបែងចែក ផ្អែកលើប្រភេទចំណាយ ប្រាក់បៀវត្សរ៍ ។ល។ ជំនួសឱ្យការបែងចែកផ្អែកលើក្រសួង ដូចដែលបានរាយការណ៍កន្លងមក ។

In January 2007, current budget expenditure decreased by 93 percent from the previous month to 25.8 billion riels. Spending on official wages was 13.7 billion riels in January 2007 and government subsidies and social assistance was 4.0 billion riels. Government budget reporting changed in January 2007, following revision and improvements by the Ministry of Economy and Finance. Now the report is divided according to spending categories, wages etc., instead of by ministry as reported previously.

**Current Budget Expenditure Components**
November 2005–January 2007




*Note: Provisional for 2006 and 2007*
Source: *Monthly Bulletin of Statistics* (MEF)

# សកម្មភាពសេដ្ឋកិច្ចនៃបណ្តាប្រទេសជាដៃគូរបស់កម្ពុជា

# Economic Activity of Selected Economic Partners of Cambodia

នៅខែមេសា ការនាំចេញទំនិញរបស់អាមេរិក និងតំបន់អឺរ៉ូ កើនឡើង រីឯការនាំចេញរបស់ជប៉ុន ថយចុះ ។ ការនាំចេញទំនិញរបស់អាមេរិក កើន ១,០% ធៀបនឹងខែមុន ដល់ ៩១,១១ពាន់លានដុល្លារ រីឯការនាំចេញទំនិញរបស់តំបន់អឺរ៉ូ កើន ១,៨% ដល់ ១៦៦,៦២ពាន់លានដុល្លារ ។ ការនាំចេញរបស់ជប៉ុន នៅខែមេសា ថយចុះអស់ ១២% ធៀបនឹងខែមុន មកត្រឹម ៥៦,០៧ពាន់លានដុល្លារ ។

In April, goods exports of the US and the Euro zone increased, while exports of Japan decreased. US goods exports rose by 1.0 percent from the previous month to USD91.11 bn, while goods exports of the Euro zone increased by 1.8 percent to USD 166.62 bn. Japan exports in April decreased by 12 percent from the previous month to USD56.07 bn.

**Goods Exports: US, Euro zone & Japan**

April 2006–April 2007




Sources: BEA, Eurostat and JETRO

នៅខែមេសា ចិនមានអតិរេកពាណិជ្ជកម្ម ១៦,៨៥ពាន់លានដុល្លារ ធៀបនឹងអតិរេក ៦,៨៧ពាន់លានដុល្លារ នៅខែមីនា ។ អតិរេកនេះ បណ្តាលជាសំខាន់មកពី ការនាំចេញកើនឡើងខ្លាំងជាងការនាំចូល ។ ការនាំចេញសរុបកើន ១៧% ធៀបនឹងខែមុន ដល់ ៩៧,៤៥ពាន់លានដុល្លារ រីឯការនាំចូលសរុប កើន ៥,៣% ដល់ ៨០,៦០ពាន់លានដុល្លារ ។

In April, China recorded a trade surplus of USD16.85 bn compared to USD6.87 bn in March. The greater surplus was due to a larger increase in exports than imports. Total exports increased by 17 percent from the previous month to USD97.45 bn, while total imports rose by 5.3 percent to USD80.60 bn.

**External Trade: China**

April 2006–April 2007




Sources: National Bureau of Statistics of China

នៅខែមេសា ម៉ាឡេស៊ីមានអតិរេកពាណិជ្ជកម្ម ១,៧៣ពាន់លានដុល្លារ ធៀបនឹងអតិរេក ១,៧៧ពាន់លានដុល្លារ នៅខែមីនា ។ ទាំងការនាំចេញ និងនាំចូល បានថយចុះបន្តិចបន្តួច ធៀបនឹងខែមុន ។ ការនាំចេញសរុប នៅខែមេសា គឺ ១៣,៣០ពាន់លានដុល្លារ ធៀបនឹង ១៤,៤៥ពាន់លានដុល្លារ នៅខែមីនា ។ ការនាំចូលសរុប គឺ ១១,៥៧ពាន់លានដុល្លារ ធៀបនឹង ១២,៥៣ពាន់លានដុល្លារ នៅខែមីនា ។

In April, Malaysia recorded a trade surplus of USD1.73 bn compared to USD1.77 bn in March. Both total exports and imports decreased modestly from the previous month. Total exports in April were USD13.30 bn, down from USD14.45 bn. in March. Total imports were USD11.57 bn, compared to USD12.53 bn in March.

**External Trade: Malaysia**

April 2006–April 2007




Source: Department of Statistics, Malaysia

# ស្ថានភាពអតិផរណានៃបណ្តាប្រទេសជាដៃគូរបស់កម្ពុជា

# Inflation Rates in Selected Economic Partners of Cambodia

ថ្លៃទំនិញប្រើប្រាស់នៅអាមេរិក កើន ២,៦% ក្នុងរយៈមួយឆ្នាំដល់ខែមេសា ។ យោងតាមក្រសួងការងារអាមេរិក កំណើននេះបណ្តាលមកពីការឡើងថ្លៃម្ហូបអាហារ ការស្នាក់នៅ និងការថែទាំសុខភាព ។ ក្នុងអំឡុងពេលដូចគ្នា អត្រាអតិផរណា គឺ ១,៩% នៅតំបន់អឺរ៉ូ និងសូន្យនៅជប៉ុន ។

US consumer prices increased by 2.6 percent in the year to April. According to the U.S Department of Labor, this increase largely reflected higher charges for food, housing and medical care. During the same period, the inflation rate was 1.9 percent in the Euro zone and nil in Japan.

### Inflation Rate: US, Euro zone & Japan

(change from a year ago)




*Note: The latest data available are for Apr. 2007*
Sources: IMF and *The Economist* (Jun. 28th 2007)

ថ្លៃទំនិញប្រើប្រាស់នៅហុងកុង កើន ១,៣% ក្នុងរយៈមួយឆ្នាំ ដល់ខែមេសា ២០០៧ ប៉ុន្តែនៅទាបជាងកំណើន ២,៤% កាលពីខែមុន ។ ក្នុងអំឡុងពេលដូចគ្នា ថ្លៃទំនិញប្រើប្រាស់នៅចិន និងកូរ៉េខាងត្បូង កើន ៣,០% និង ២,៥% ។

Hong Kong's consumer prices rose by 1.3 percent in the year to April 2007, lower than the 2.4 percent increase of a month earlier. During the same period, consumer prices in both China and South Korea increased by 3.0 percent and 2.5 percent respectively.

### Inflation Rate: China, Hong Kong & South Korea

(change from a year ago)




*Note: The latest data available are for Apr. 2007*
Sources: IMF and *The Economist* (Jun. 28th 2007)

នៅខែមីនា ឆ្នាំ២០០៧ សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់នៅសិង្ហបុរី គឺ ០,៦% ខ្ពស់ជាងខែដូចគ្នាឆ្នាំមុន ។ យោងតាមនាយកដ្ឋានស្ថិតិសិង្ហបុរី កំណើននេះបណ្តាលមកពី ការឡើងថ្លៃម្ហូបអាហារ សំលៀកបំពាក់ ស្បែកជើង ការថែទាំសុខភាព និងការលំហែកំសាន្ត ។ ក្នុងអំឡុងពេលដូចគ្នា អត្រាអតិផរណាពីមួយឆ្នាំទៅមួយឆ្នាំ គឺ ១,៥% នៅម៉ាឡេស៊ី និង ១,៨% នៅថៃ ។

Singapore's consumer price index in March 2007 was 0.6 percent higher than the same month a year earlier. The Department of Statistics of Singapore attributed this to higher costs for food, clothing and footwear, healthcare, and recreation. During the same period, the year-on-year inflation rate was 1.5 percent in Malaysia and 1.8 percent in Thailand.

### Inflation Rate: Selected ASEAN Countries

(change from a year ago)




*Note: The latest data available are for Apr. 2007*
Sources: IMF and *The Economist* (Jun. 28th 2007)

# អត្រាប្តូរប្រាក់លើទីផ្សារអន្តរជាតិ

# Exchange Rates in World Markets

នៅខែមិថុនា ឆ្នាំ២០០៧ ដុល្លារUS ឡើងថ្លៃទល់នឹងរូបិយវត្ថុចំបងៗភាគច្រើន ។ ទល់នឹងប្រាក់អឺរ៉ូ វាប្តូរបាន ០,៧៥អឺរ៉ូ/ដុល្លារUS រឺ ឡើងថ្លៃប្រហែល ១% ធៀបនឹងខែមុន ។ ទល់នឹងប្រាក់យ៉េនជប៉ុន វាប្តូរបាន ១២២,៧យ៉េន/ដុល្លារUS រឺ ឡើងថ្លៃ ១,៦% ធៀបនឹងខែមុន ។

In June 2007, the US dollar advanced against most major currencies. Against the euro, it traded at 0.75 EUR/USD, about one percent appreciation from a month earlier. Against the Japanese yen, it exchanged at 122.7 JPY/USD, another 1.6 percent gain compared to the preceding month.

### EUR & JPY Per USD

Jun 06–Jun 07 (Monthly average)




Source: Federal Reserve Bank of New York

នៅខែមិថុនា ឆ្នាំ២០០៧ ប្រាក់វ៉ុនកូរ៉េខាងត្បូង ប្តូរបាន ៩២៧,៥៨វ៉ុន/ដុល្លារUS គឺមិនមានការប្រែប្រួលទេ ធៀបនឹងខែឧសភា ឆ្នាំ២០០៧ ។ ក្នុងអំឡុងពេលដូចគ្នា ដុល្លារហុងកុង ក៏មានស្ថិរភាពល្អដែរទល់នឹងដុល្លារUS ដោយប្តូរបាន ៧,៨១ដុល្លារហុងកុង/ដុល្លារUS ។

In June 2007, the South Korean won exchanged at 927.58 KRW/USD against the US dollar, showing no change from May 2007. During the same period, the Hong Kong dollar remained steady against its US counterpart, trading at 7.81 HKD/USD.

### KRW & HKD Per USD

Jun 06–Jun 07 (Monthly average)




Source: Federal Reserve Bank of New York

នៅខែមិថុនា ឆ្នាំ២០០៧ ដុល្លារសិង្ហបុរី ចុះថ្លៃតិចតួចទល់នឹងដុល្លារUS ដោយវាបានចុះអស់ពីរខែបន្តបន្ទាប់ ។ វាប្តូរបាន ១,៥៣៧ដុល្លារសិង្ហបុរី/ដុល្លារUS ។ ប្រាក់បាតថៃ ឡើងថ្លៃបន្តិចទល់នឹងដុល្លារUS ដោយប្តូរបាន ៣២,៣២បាត/ដុល្លារUS រឺ ឡើងថ្លៃ ១,៥% ធៀបនឹងខែឧសភា ឆ្នាំ២០០៧ ។

In June 2007, the Singapore dollar rate fell slightly against the US dollar for a second month in succession. It traded at 1.537 SGD/USD. The Thai baht slightly advanced against the US dollar, exchanging at 32.32 THB/USD, a 1.5 percent appreciation from May 2007.

### THB & SGD Per USD

Jun 06–Jun 07 (Monthly average)




Source: Federal Reserve Bank of New York

# ស្ថានភាពតំលៃទំនិញលើទីផ្សារអន្តរជាតិ
# Commodity Prices in World Markets

នៅខែឧសភា ថ្លៃអង្ករពិភពលោកមិនមានការប្រែប្រួលទេ ។ សន្ទស្សន៍ថ្លៃអន្តរជាតិ (IPO) នៅនឹងដដែលដូចខែមុន នៅកំរិត ១៣៧,៦ពិន្ទុ ។ នៅថៃ ថ្លៃអង្ករ ១០០%B កើនបន្តិចដល់ ២៩៥,៦៨ដុល្លារ/តោន ធៀបនឹង ២៩៣,៨៦ដុល្លារ/តោន នៅខែមេសា ។ នៅ US ថ្លៃអង្ករនាំចេញថយចុះ ១,៧% ធៀបនឹងខែមុន មកត្រឹម ៣៧៦,៤១ដុល្លារ/តោន ។

In May, world rice prices were stable. The International Prices Index (IPO) remained the same as the previous month at 137.6. In Thailand, the price of Thai 100%B rose slightly to USD295.68 per tonne from USD293.86 in April. In the United States, the export price decreased by 1.7 percent from the previous month to USD376.41 per tonne.

**Rice: International Prices Index & Export Prices**
May 2006–May 2007




Sources: Osiriz/InfoArroz and InterRice.

នៅខែមិថុនា ថ្លៃសណ្តែកសៀង និងពោតកើនឡើង ។ សណ្តែកសៀងលក់បាន ២៧៧,៣៨ដុល្លារ/តោន ដោយកើនពី ២៥៥,១៥ដុល្លារ/តោន នៅខែឧសភា ។ ពោតលក់បាន ១៥៤,៣០ដុល្លារ/តោន គឺបានថ្លៃជាងកំរិត ១៤៤,៦៤ ដុល្លារ/តោន នៅខែឧសភា ។ នៅខែឧសភា ថ្លៃប្រេងឆា កើន ៨,៧% ធៀបនឹងខែមុន ដល់ ៧០០,២០ដុល្លារ/តោន ។

In June, the prices of soybeans and maize increased. Soybeans sold at USD277.38 per tonne, up from USD255.15 per tonne in May. Maize was USD154.30 per tonne, up from USD144.64 per tonne in May. In May, the price of palm oil increased by 8.7 percent from the previous month to USD700.20 per tonne.

**Prices: Soybeans, Maize & Palm Oil**
June 2006–June 2007




Source: Food and Agriculture Organisation (FAO)

នៅខែមិថុនា ថ្លៃប្រេងឆៅ និងម៉ាស៊ូត កើនឡើង ឯថ្លៃសាំងថយចុះ ។ ថ្លៃប្រេងឆៅលក់ដល់ដៃរបស់ OPEC គឺ ៦៧ដុល្លារ/ធុង ធៀបនឹង ៦៤,៨២ដុល្លារ នៅខែឧសភា ។ ថ្លៃសាំងធម្មតា (អុកតាន ៨៧) នៅ US Gulf Coast ធ្លាក់ចុះ ៦,៤% ធៀបនឹងខែមុន មកត្រឹម ៥៧,២៦សេន/លីត្រ ។ ថ្លៃម៉ាស៊ូត (មានលាយស្ពាន់ធ័រតិច លេខ២) នៅ US Gulf Coast កើន ៣,៥% ធៀបនឹងខែមុន ដល់ ៥៤,៦៣សេន/លីត្រ ។

In June, the prices of crude oil and diesel increased, while the price of gasoline decreased. The OPEC spot price of crude oil was USD67.00 per barrel, against USD64.82 in May. Regular gasoline (87 octane) prices on the US Gulf Coast went down by 6.4 percent from the previous month, to 57.26 cents per litre. Diesel (low sulphur No.2) on the US Gulf Coast rose by 3.5 percent from the previous month, to 54.63 cents per litre.

**Prices: Crude Oil, Gasoline & Diesel**
June 2006–June 2007




Source: US Energy Information Administration

# ព័ត៌មានសេដ្ឋកិច្ច

# Economic News

***កម្ពុជា នឹងបង្កើតផ្សារហ៊ុននៅឆ្នាំ២០០៩:*** នៅថ្ងៃទី ៧ មិថុនា ២០០៧ ក្នុងសន្និសីទមួយនាក្រុងភ្នំពេញ ស្តីពី ភាពជាដៃគូរវាងរដ្ឋាភិបាល និងធនាគារអភិវឌ្ឍន៍អាស៊ី (ADB) សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន បានលើកពីគំរោងបង្កើតផ្សារហ៊ុនក្នុងក្របខ័ណ្ឌតូចមួយនៅឆ្នាំ២០០៩ ដើម្បីលើកទឹកចិត្តសាធារណជនឱ្យធ្វើវិនិយោគរយៈពេលវែង ហើយសព្វថ្ងៃរដ្ឋាភិបាលកម្ពុជាកំពុងបង្ហើយសេចក្តីព្រាងច្បាប់ស្តីពីសញ្ញាប័ណ្ណក្រុមហ៊ុន។ សម្តេចបានបន្ថែមថាការបង្កើតទីផ្សារហិរញ្ញវត្ថុមានសារៈសំខាន់ណាស់ ដោយវាអាចជួយប្រមូលប្រាក់សន្សំរបស់ប្រជាជនកម្ពុជា យកទៅបំរើវិនិយោគរយៈពេលវែងនៅក្នុងគំរោងសង្គមកិច្ច សេដ្ឋកិច្ច និងហេដ្ឋារចនាសម្ព័ន្ធ ។ មូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) បានបញ្ជាក់កាលពីដើមសប្តាហ៍នេះថា វិស័យហិរញ្ញវត្ថុកម្ពុជាកំពុងរីកធំធាត់ ដោយមានប្រាក់បញ្ញើ និងកំចីធនាគារថ្មីៗកើនឡើងប្រហែល ៤០% ដែលជួយជំរុញដល់ការអភិវឌ្ឍន៍បន្ថែមទៀត។

***Cambodia to establish stock market in 2009:*** Cambodia will establish a limited stock market in 2009 and this would encourage long-term investments by the public, Prime Minister Hun Sen said at a symposium on the partnership between the government and the Asian Development Bank (ADB) on 7 June 2007 in Phnom Penh. The Cambodian government, which is currently finalizing draft legislation on corporate bonds, aims to establish a capital market in 2009.The introduction of a financial market is very important, he said, adding that it can help to mobilize the Cambodian people's savings and channel them into long-term investments in social, economic and infrastructure projects. The Cambodian finance sector is expanding, with new bank loans and deposits increasing by around 40 percent, setting the stage for further development, the International Monetary Fund (IMF) said earlier this week. *(Cited from Xinhua, 7 June 2007)*

***ធនាគារពិភពលោក បង្ហាញកម្មវិធីសំរាប់អោយកម្ពុជាទទួលបានអគ្គិសនីមានតំលៃថោក និងធានាគុណភាព :*** ជាចំនែកមួយនៃកម្មវិធីអគ្គិសនីភាវូបនីយកម្មក្នុងតំបន់ ធនាគារពិភពលោក (WB) បានសំរេចចិត្តផ្តល់ជំនួយឥតសំណង ១៨,៥លានដុល្លារ សំរាប់កសាងខ្សែបញ្ជូនអគ្គិសនីឆ្លងកាត់ព្រំដែនទៅឡាវ និងវៀតណាម ដែលអាចជួយកាត់បន្ថយថ្លៃអគ្គិសនីដ៏ខ្ពស់នៅតាមខេត្តឆ្ងាយៗ ។ លោក Ian Porter នាយកប្រចាំនៅកម្ពុជានៃ WB បានបញ្ជាក់ថា យុទ្ធសាស្រ្តពាណិជ្ជកម្មថាមពលរបស់ WB សំរាប់មហាអនុតំបន់មេគង្គ (GMS) មានគោលដៅបង្កើនកិច្ចសហប្រតិបត្តិការ និងសមាហរណកម្មក្នុងតំបន់ ។ លោក Mohinder Gulati អ្នកឯកទេស ខាងថាមពលក្នុងកម្មវិធីនេះ បានបញ្ជាក់ថា ពាណិជ្ជកម្មថាមពលអាចផ្តល់អត្ថប្រយោជន៍សំខាន់ៗខាងសេដ្ឋកិច្ច និងបរិស្ថាន និងបង្កើនសុវត្ថិភាពថាមពល នៅក្នុង GMS ។

***WB presents program for Cambodia to get cheap, reliable electricity:*** As part of a regional electrification program, the World Bank (WB) has decided to grant 18.5 million U.S. dollars to Cambodia for the construction of a cross-border transmission line to Vietnam and Laos, hoping to reduce high electricity fees in remote provinces. Ian Porter, the World Bank country director for Cambodia, said that the bank's Power Trade strategy for the Greater Mekong Sub-region (GMS) is aimed at beefing up cooperation and regional integration. "Power trade in the GMS can bring major economic and environmental benefit and improve energy security in the Mekong sub-region," said Mohinder Gulati, lead energy specialist for the program. *(Cited from Xinhua, 07 June 20077)*

***កម្ពុជា និងជប៉ុនចុះហត្ថលេខាលើកិច្ចព្រមព្រៀងវិនិយោគ :*** សម្តេច ហ៊ុន សែន នាយករដ្ឋមន្ត្រីកម្ពុជា និងលោក Shinzo Abe នាយករដ្ឋមន្ត្រីជប៉ុន បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងមួយ នៅថ្ងៃទី ១៤ មិថុនា ២០០៧ នាទីក្រុងតូក្យូ ដើម្បីជំរុញវិនិយោគជប៉ុននៅប្រទេសកម្ពុជា ។ កិច្ចព្រមព្រៀងមានសេចក្តីចែងមួយថា ក្រុមហ៊ុនជប៉ុនត្រូវស្ថិតក្រោមរបបច្បាប់ និងការយកពន្ធ ដូចគ្នានឹងក្រុមហ៊ុនកម្ពុជាដែរ នៅពេលធ្វើប្រតិបត្តិនៅកម្ពុជា ។ សេចក្តីចែងមួយទៀតបានហាមឃាត់ក្រុមហ៊ុនកម្ពុជា ធ្វើការតំរូវដល់ក្រុមហ៊ុនជប៉ុននៅកម្ពុជាឱ្យផ្ទេរបច្ចេកវិទ្យា រឺ ទទួលយកសំភារៈផ្គត់ផ្គង់ដែលមាននៅក្នុងប្រទេសកម្ពុជា។ មន្ត្រីជប៉ុនបានប្រាប់ថា ជប៉ុននឹងបញ្ជូនបេសកកម្មពាណិជ្ជកម្មមួយ ដែលមានសមាសភាពជាតំណាងមកពីខាងរដ្ឋាភិបាល និងវិស័យឯកជន មកកម្ពុជានៅខែក្រោយ ដើម្បីពិភាក្សាពីឱកាសសំរាប់ធ្វើសហប្រតិបត្តិការសេដ្ឋកិច្ច ។

***Cambodia, Japan sign investment agreement:*** Cambodian and Japanese Prime Ministers, Hun Sen and Shinzo Abe, signed an agreement on 14 June 2007 in Tokyo encouraging Japanese investment in the South-East Asian nation. One stipulation of the agreement is that Japanese firms will receive the same treatment for regulation and taxation as Cambodian firms when they operate in the country. Another is to ban Cambodian companies from requiring Japanese firms in the country to transfer technology or obtain supplies within Cambodia. According to Japanese officials, Japan will dispatch "a business mission composed of representatives from both the government and private sector" to Cambodia next month to discuss opportunities for economic cooperation. *(Cited from Xinhua, 15 June 20077)*